**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ ៤៣៩/២៣ ក. ស. ភ.

ថ្ងៃ សុក្រ ៨ រោច ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព. ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារពេលក្នុងការចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ របស់ កំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា **របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣** របស់ ក.ស.ភ. នឹងត្រូវពន្យារពេលក្នុងការចេញផ្សាយរហូតដល់ **ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣** វិញ។ ការពន្យារពេលនេះ ដោយហេតុថាសវនករឯករាជ្យ KPMG បានកត់សម្គាល់ឃើញថា មានគណនីមួយចំនួនដែល ក.ស.ភ. បានកត់ត្រានៅក្នុងបញ្ជិកាគណនេយ្យ តម្រូវឱ្យធ្វើការរាយការណ៍ឡើងវិញ (Restatement)។ ដូចនេះ សវនករឯករាជ្យនឹងត្រូវចំណាយពេលវេលាក្នុងការត្រួតពិនិត្យ និងសាកសួរបន្ថែមចំពោះករណីនេះ ដើម្បីអាចធ្វើការបញ្ចប់នូវការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ បាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ តីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh